# I ទីស្តីការគណៈរដ្ឋមន្ត្រី

## ១- អនុក្រឹត្យ

*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៤*

### អនុក្រឹត្យលេខ ៧៩ អនក្រស្តីអំពី បែបបទចេញចូល សំរាប់អ្នកទេសចរណ៍បរទេស

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល

-បានឃើញច្បាប់ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើ ដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញសេចក្តីសំរេចរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៤ ស្តីអំពីបញ្ហាទិដ្ឋាការ

-យោងស្មារតី ប្រជុំអន្តរក្រសួងនាថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤

-យោងតាមសំណូមពរ ការងារចាំបាច់

**សំរេច**

**មាត្រា ១ :** អ្នកទេសចរណ៍បរទេស ដែលមានសំបុត្រយន្តហោះត្រឡប់ទៅវិញ ត្រូវចាត់ទុកដូចជាអ្នកដំណើរឆ្លងកាត់ អាចស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនលើសពីចំនួន ១៥ ថ្ងៃ ។

**មាត្រា ២ :** ការបំពេញបែបបទ នឹងត្រូវធ្វើដោយអាជ្ញាធរ មានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា នៅព្រលានយន្តហោះពោធិចិនតុង ។

មាត្រា ៣ : ការសុំពន្យាពេលដោយមិនបាច់បង់ថ្លៃដែលមានកំណត់ពេលមិនហួសពី ៧ ថ្ងៃធ្វើទៅបានតែក្នុងករណីប្រធានសក្តិចាំបាច់។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានសិទ្ធិសំរេចក្នុងរឿងនេះ ។

មាត្រា ៤ : អ្នកទេសចរណ៍បរទេស ដែលមានការអនុញ្ញាតិអោយស្នាក់នៅចំនួន ១៥ ថ្ងៃហើយបានចាកចេញទៅកាន់ប្រទេសមួយទៀតមុន ១៥ ថ្ងៃឬក្រោយ ១៥ ថ្ងៃហើយ ត្រឡប់មកកាន់ព្រះរាជាណាចក្រកម្ពុជាវិញ មួយថ្ងៃបន្ទាប់ឬច្រើនថ្ងៃបន្ទាប់មកត្រូវបានទទួលការអនុញ្ញាតិ អោយស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា ១៥ ថ្ងៃ ជាថ្មីទៀត ។ ការផ្តល់ការអនុញ្ញាតិទាំងមុនទាំងក្រោយនេះត្រូវធ្វើបាន តែចំនួន ២ ដងគត់ ក្នុងរយៈពេល ៦ ខែ ។

មាត្រា ៥ : អ្នកទេសចរណ៍បរទេសដែលចង់បន្តទិដ្ឋាកា លើសពីចំនួន ១៥ ថ្ងៃដែលបានអនុញ្ញាតិនេះ ត្រូវធ្វើការសុំពន្យាពេល និង ត្រូវបង់ថ្លៃទិដ្ឋាការពន្យាតាម ការកំណត់នៃក្រសួងមានសមត្ថកិច្ច ។

មាត្រា ៦ : អ្នកទេសចរណ៍បរទេស ដែលមានចែងក្នុងមាត្រា ១ ចាប់តាំងពីអាយុ ៨ ឆ្នាំឡើងទៅ ត្រូវបង់អាករចេញចូល ១៥ ដុល្លារអាមេរិក និងអាករព្រលានយន្តហោះ ១០ ដុល្លារអាមេរិក រាល់ពេល ចេញដំណើរ អំពីព្រលានយន្តហោះ ដើម្បីទៅកាន់អន្តរជាតិ ។

មាត្រា ៧ : អ្នកទេសចរណ៍បរទេសធ្វើដំណើរចុះឡើងក្នុងប្រទេសតាមយន្តហោះត្រូវបង់អាករព្រលានយន្តហោះ នៅរាល់ពេលចេញដំណើរចំនួន ៤ ដុល្លារអាមេរិកម្នាក់ចាប់តាំងពីអាយុ ៨ ឆ្នាំឡើងទៅ ។

មាត្រា ៨ : ប្រជាពលរដ្ឋខ្មែរចាប់តាំងពីអាយុ ៨ ឆ្នាំឡើងលើត្រូវបង់អាករព្រលានយន្តហោះ ១០ ដុល្លារអាមេរិកម្នាក់ក្នុងការធ្វើដំណើរ ទៅកាន់បរទេសតាមយន្តហោះ ។ ចំនួន ៤ ដុល្លារអាមេរិក ម្នាក់ក្នុងការធ្វើដំណើរក្នុង ស្រុកតាមយន្តហោះ ។

មាត្រា ៩ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និង សេដ្ឋកិច្ច អនុរដ្ឋលេខាធិការ អាកាសចរណ៍ស៊ីវិល និង រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ត្រូវទទួលភារៈរៀងខ្លួនចាត់ការអោយបានសំរេចតាមអនុក្រឹត្យនេះ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និងត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * * *

*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៧៥ អនក្រ
## ស្តីពីការធ្វើនិយ័តភាពថវិកា ឆ្នាំ ១៩៩៤
## របស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣